# រឿងអាឡវិកាភិក្ខុនី (បិដក៣០ ទំព័រ១)

# (បិដក អដ្ឋកថា ដីកា)



រៀបរៀងនិងប្រែដោយ ភិក្ខុ **សារត្ថធម្មោ នួន សារ៉េត** ព.ស២៥៦៧ គ.ស២០២៣

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទានដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

# អាឡវិកាសូត្រ ទី១ (បិដក)

[១] ខ្ញុំបានស្តាប់មក យ៉ាងនេះ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះ ភិក្ខុនីឈ្មោះអាឡវិកា ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងបច្ឆាភត្ត ក៏មានសេចក្តីត្រូវការ ដោយទីស្ងាត់ ហើយចូលទៅកាន់អន្ធវ័ន។

[២] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាឡវិកាភិក្ខុនី មានប្រាថ្នាឲ្យនាងឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ ហើយក៏ចូលទៅរកអាឡវិកាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងអាឡវិកាភិក្ខុនីថា ធម្មជាតជាគ្រឿងរលាស់ចេញ [ព្រះនិព្វាន។] ក្នុងលោក មិនមានទេ នាងនឹងធ្វើនូវប្រយោជន៍អ្វី ដោយសេចក្តីស្ងប់ស្ងាត់ ចូរនាងបរិភោគ នូវសេចក្តីត្រេកអរក្នុងកាម នាងពុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ។

[៣] គ្រានោះ អាឡវិកាភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា។ ទើបអាឡវិកាភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ

សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើង ដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញ ឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ បានជាពោលនូវគាថា។ លុះអាឡវិកាភិក្ខុនីស្គាល់ច្បាស់ថា នេះជាមារ មានចិត្តបាប ដូច្នេះហើយ ក៏ពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា ធម្មជាត ជាគ្រឿងរលាស់ចេញក្នុងលោក មាន យើងបានពាល់ត្រូវដោយបញ្ញា [បច្ចវេក្ខណញ្ញាណ។] ម្នាលមារមានចិត្តបាប មានផៅពង្សជាអ្នកប្រមាទ អ្នកមិនដឹងនូវបទនោះទេ កាមទាំងឡាយ ឧបមាដោយលំពែងស្រួច ខន្ធទាំងឡាយជាកន្ទែងសម្រាប់មុត នៃកាមទាំងឡាយនោះ អ្នកពោលនូវសេចក្តីត្រេកអរ ក្នុងកាមណា សេចក្តីត្រេកអរ ក្នុងកាមនោះ ជាសេចក្តីមិនត្រេកអរ របស់យើងទេ។

លំដាប់នោះ មារមានចិត្តបាបដឹងថា អាឡវិកាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ។

(ចប់ក្នុងបិដក)

# អ ដ្ឋ ក ថា

## អាឡវិកាសូត្រទី ១

ក្នុងភិក្ខុនីសំយុត្ត **អាឡវិកាសូត្រទី ១** មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១]** បទថា **អាឡវិកា** សេចក្ដីថា អ្នកកើតក្នុងក្រុងអាឡវី និងចេញបួសពីក្រុងអាឡវីនុ៎ះឯង ។ បទថា **អន្ធវ័ន** សេចក្ដីថា ព្រៃដែលឈ្មោះថា អន្ធវ័ន តាំងពីវេលាដែលពួកចោរ ៥០០ នាក់ ខ្វេះភ្នែកទាំងពីររបស់ព្រះអរិយបុគ្គល (អនាគាមី) អ្នកពោលធម៌ នាមថា **យសោធរ** ជាអ្នកប្រមូលទ្រព្យមកដើម្បីសាងព្រះចេតិយព្រះសម្មាសម្ពុទ្ធព្រះនាមថា **កស្សប** ខ្លួនឯងក៏បែកភ្នែកទៅក្នុងទីនោះឯង ។ គេដំណាលមកថា ព្រៃនោះ ជាព្រៃរក្សានូវពួកម្រឹគ ក្នុងផ្ទៃដីប្រមាណមួយគាវុត ផ្នែកទិសទក្សិណក្រុងសាវត្ថី បុគ្គលដែលត្រូវការវិវេក និងភិក្ខុនីទាំងឡាយ ក៏នាំគ្នាទៅក្នុងព្រៃនោះ ។ ព្រោះដូច្នោះ សូម្បីភិក្ខុនីអាឡវិកានេះ ក៏មានសេចក្ដីត្រូវការវិវេក ទើបចូលទៅកាន់ព្រៃនោះ ។

**[៣]** បទថា **និស្សរណំ** បានដល់ ព្រះនិព្វាន ។ បទថា **បញ្ញាយ**

បានដល់ បច្ចវេក្ខណញ្ញាណ ។ បទថា **ឧ តុំ ជាតាសិ តំ បទំ** សេចក្តីថា អ្នកមិនដឹងបទ គឺ ព្រះនិព្វាន ឬបទ គឺ មគ្គ ដែលទៅកាន់ព្រះនិព្វាន ។ បទថា **សត្តិសូលូបមា** បានដល់ ដូចជាលំពែង និងដែកស្រួច ព្រោះអត្ថថា ជាគ្រឿងចាក់ដោត ។ បទថា **ខន្ធាសំ អធិកុដ្ដនា** សេចក្តីថា គំនរនៃកាមទាំងឡាយនោះ ដូចជាឬស ។

ចប់អដ្ឋកថា អាឡវិកាសូត្រទី ១

# អាឡវិកាសូត្រទី១ (ដីកា)

(១) ពីរបទថា កើតហើយក្នុងដែនអាឡវី មានសេចក្តីថា ប្រសូតចម្រើនឡើងហើយក្នុងដែនអាឡវី ។ ព្រោះហេតុនោះ បានជាលោកអាចារ្យពោលថា បព្វជិតទាំងឡាយ រមែងចាកចេញអំពីដែនអាឡវី ។ កាលដែលគេធ្វើនវកម្មបួនមុខ កម្ម គឺលោកសេដ្ឋីមានគ្រហស្ថជាប្រធានអន់ថយ មានឧបាសកជាអរិយសាវ័កមួយនាក់ ទឹមដោយរទេះ ៥០០ ហើយបរទៅកាន់ជនបទដោយគិតយ៉ាងនេះថា ព្រះរាជាបានថ្វាយវត្ថុមួយមុខចំពោះព្រះចេតិយ បានជាព្រះរាជបុត្រមួយអង្គ, សេនាបតីមួយនាក់ បានជាច្បងនៃអាមាត្យទាំងឡាយ, លោកសេដ្ឋីមួយនាក់ បានជាច្បងនៃអ្នកជនបទទាំងឡាយ ។ ហើយញ៉ាំងគេឲ្យកាន់យកនូវកម្មដ្ឋាន ហើយបញ្ជូននូវកម្មដ្ឋានជាដំបូងតាមសមគួរ ដោយបំណងថា បុគ្គលណាព្យាយាមឲ្យនូវវត្ថុណា ទោះបីជា មាសក្តី ប្រាក់ក្តី រតនៈប្រាំពីរប្រការក្តី ហរិតាល (វត្ថុមួយប្រភេទស្មើរជាថ្មតែទន់សម្បុរលឿងខ្ចី)ក្តី ថ្មមនោសិលា (ម្នាងសិលា)ក្តី បុគ្គលនោះ ចូរឲ្យនូវទ្រព្យចុះ។ តពីនោះមក ពួកចោរទាំងឡាយកាលមកតាមផ្លូវ បានស្តាប់ឮថា នវកម្មសម្រេចហើយ បានដេញតាមក្រោយ (នៃសេដ្ឋីនោះ) កាលមិនបាននូវទ្រព្យ បានគិតថា អញនឹងញ៉ាំងសេដ្ឋីចាកជីវិត ប្រសិនបើ អញនឹងធ្វើនូវសេដ្ឋីនោះចាកជីវិត ពួកយើងឈ្មោះថា គប្បីធ្វើកម្មមិនជាប្រយោជន៍ ។ ពួកចោរទាំងឡាយនោះ ជាអ្នកមានទោសក្នុងគុណព្រះអរិយបុគ្គលដោយពិត

ព្រោះជាបុគ្គលល្ងីតល្ងង់ ។ ព្រោះហេតុនោះ ទើបអដ្ឋកថាពោលប្រាកដថា ព្រៃផងឹត ។ បុគ្គលជាព្រះខីណាស្រពពួកខ្វះ ជាចិត្តវិវេកតែម្យ៉ាង ព្រោះភាវៈនៃឧបធិវិវេក ។ ព្រោះហេតុនោះ ទើបលោកពោលថា កាយវិវេក ។

បទថា នូវការអាស្រ័យ មានសេចក្តីថា ព្រោះភាវៈនៃការអាស្រ័យនូវព្រះនិព្វានជាបច្ច័យតាក់តែងទាំងពួង ។

បទថា បច្ចវេក្ខណញ្ញាណ មានសេចក្តីថា ដោយការពិចារណា ។ អធិប្បាយថា ពុំចាំបាច់ពោលថ្វីដោយមគ្គញ្ញាណ និង ផលញ្ញាណ ។

បទថា និព្វានបទ មានសេចក្តីថា ចំណែកនៃធម៌ ពោលគឺព្រះនិព្វាន ។

បទថា ដោយការជ្រាបច្បាស់ មានសេចក្តីថាកាមគុណប្រាំនៃខន្ធទាំងឡាយនោះ ដោយការកើតឡើងនៃទុក្ខ ហើយជ្រាបច្បាស់ក្នុងហ្ឫទ័យ ព្រោះការជ្រាបច្បាស់ក្នុងហ្ឫទ័យ ឈ្មោះថា ប្រាកដស្មើដោយចុងនៃដែកស្រួច។ ការចងអាឃាត ឈ្មោះថា អធិកុដ្ដនកណ្ឌិក ។

អាឡវិកាភិក្ខុនីសូត្រ ចប់